# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ លទ្ធផលរំពឹងទុកសំរាប់ផែនការប្រចាំឆ្នាំ ២០១០

## ផ្នែកទី១: កិច្ចគាំទ្រការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើត សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តាមវិស័យនានាអោយបានទូលំទូលាយ

**លទ្ធផលរំពឹងទុក**

| | | |
|---|---|---|
| **១.១** | **គាំទ្រតួនាទីសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អោយមានប្រសិទ្ធិភាព** | **អគ្គលេខាធិការដ្ឋាន**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១០-២០១៤: គោលបំណងទី៣<br>គោលដៅ៣.១ , ៣.៣<br><br>យុទ្ធសាស្ត្រចតុកោណ នៃ NSDP-LJR<br>**LJRS PA 7.6.2**<br>**LJRS PA 1.4.5** |
| ១.១.១ | ផ្តល់យោបល់បច្ចេកទេសដល់ក្រុមការងារបច្ចេកទេសចំរុះ និងក្រុមពាក់ព័ន្ធផ្សេងៗទៀត ។ | |
| ១.១.២ | ផ្តល់ការបណ្តុះបណ្តាលនិងជំនួយបច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍន៍សមត្ថភាពអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ | |
| ១.១.៣ | ផ្តល់ជំនួយបច្ចេកទេសបន្តបន្ទាប់យោងតាមសំណើរ ដើម្បីគាំទ្រតួនាទីរបស់ AusAIDដែលជាសហប្រធាន ក្រុមការងារបច្ចេកទេសចំរុះ និងតួនាទីសម្របសម្រួលក្នុងវិស័យ ។ | |
| ១.១.៤ | ផ្តល់ការគាំទ្រផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ដូចជា ចែកចាយព្រឹត្តិប័ត្រកំណែទម្រង់ ច្បាប់ និងតុលាការ បច្ចុប្បន្នភាពវេបសាយរបស់អគ្គលេខាធិការដ្ឋាន និងសម្របសម្រួលកិច្ចពិគ្រោះ យោបល់រវាង រដ្ឋាភិបាល និង សង្គមស៊ីវិល តាមរយៈ វេទិការពិគ្រោះយោបល់) ។ | |
| ១.១.៥ | គាំទ្រកិច្ចពិគ្រោះយោបល់នៅថ្នាក់ជាតិ (សិក្ខាសាលាថ្នាក់ជាតិ) | |
| **១.២** | **គាំទ្រការអនុវត្តការធ្វើផែនការសម្រាប់ស្ថាប័នក្នុងវិស័យយុត្តិធម៌** | **អគ្គលេខាធិការដ្ឋាន**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១០-២០១៤: គោលបំណងទី១<br>គោលដៅ១.៤<br>**LJRS PA 7.5.1** |
| ១.២.១ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីបញ្ចប់និងគាំទ្រការអនុវត្តការធ្វើផែនការសម្រាប់ស្ថាប័នក្នុងវិស័យុត្តិធម៌ នៅតាមភ្នាក់ងារដែលជាដៃគូ ដោយប្រើប្រាស់គ្រូបង្គោល ដែលបានបណ្តុះបណ្តាលរួច ដើម្បីបណ្តុះបណ្តាលបន្តដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ | |
| **១.៣** | **រៀបចំបង្កើត និងអនុវត្តប្រព័ន្ធសូចនាករសមិទ្ធកម្មគន្លឹះតាមវិស័យ** | **អគ្គលេខាធិការដ្ឋាន**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១០- |
| ១.៣.១ | សហការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីផ្តល់ការគាំទ្របច្ចេកទេស សំរាប់ការរៀបចំប្រព័ន្ធសូចនាករ និងតាមដាន ។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| ១.៣.២ | ផ្តល់ការគាំទ្របច្ចេកទេសដើម្បីត្រួតពិនិត្យឡើងវិញនូវដៃគូអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន និង ព័ត៌មានតាមស្ថាប័ន ពីការសម្រេចគោលដៅយុទ្ធសាស្ត្រនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។ | ២០១៤: គោលបំណងទី២<br>គោលដៅ២.២<br>**LJRS PA 7.4.1** |
| **១.៤** | **ផ្តល់ការគាំទ្រចំពោះការងារប្រសិទ្ធិភាពជំនួយ និងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន តាមក្រសួង ស្ថាប័ននានា** | **អគ្គលេខាធិការដ្ឋាន**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១០-២០១៤: គោលបំណងទី៣<br>គោលដៅ៣.៤<br>**NSDP – PFMR**<br>**NSDP – AR**<br>**LJRS PA 7.7.1**<br>**LJRS PA 7.6.2**<br>**NSDP – LJR:** ពន្លឿនកំណែទម្រង់ |
| ១.៤.១ | ជួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងការសម្របសម្រួលការងារ របស់ដៃគូអភិវឌ្ឍន៍ និងក្រសួងនានា លើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ | |
| ១.៤.២ | គាំទ្រការការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុង ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ។ | |
| ១.៤.៣ | គាំទ្រការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ-លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ/កន្សោមអាទិភាព សំរាប់តួនាទីដែលទទួលបានប្រាក់ឧបត្ថម្ភបន្ថែមពីគម្រោង CCJAP ។ | |

## ផ្នែកទី២: ទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍

បង្កើតសកម្មភាពទប់ស្កាត់បទល្មើសនិងរក្សាសុវត្ថិភាពសហគមន៍ដោយមានការសហការនិងនិរន្តរភាព និងលើកកំពស់សុវត្ថិភាព សហគមន៍នៅក្នុងស្រុកគោលដៅ

លទ្ធផលរំពឹងទុក

| | | |
|---|---|---|
| **២.១** | **ពង្រឹងយន្តការសម្របសម្រួលនិងទំនាក់ទំនង នៅខេត្តដែលជាដៃគូ ដើម្បីអនុវត្តសកម្មភាព កំណែទម្រង់** | **គ.ជ.អ.ប** លទ្ធផលរំពឹងទុក លេខ ១ និងលេខ ២<br>**LJRS PA 7.6.2** |
| ២.១.១ | គាំទ្រគណៈកម្មាធិការខេត្តដែលជាដៃគូ ក្នុងការសម្របសម្រួលយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ វិមជ្ឈការនិងវិសហមជ្ឈការ និងការអនុវត្តសកម្មភាពគម្រោង CCJAP ដោយស្របតាមអនុស្សរណៈនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារួច ។ | |
| ២.១.២ | គាំទ្រគណៈកម្មាធិការថ្នាក់ក្រោមជាតិ នៅក្នុងស្រុក និងឃុំដែលជាដៃគូ ដើម្បីអនុវត្តសកម្មភាពគម្រោង CCJAP ។ | |
| ២.១.៣ | សហការជាមួយសមភាគី និងភ្នាក់ងារដែលជាដៃគូសំខាន់ៗនៅថ្នាក់ក្រោមជាតិ (នគរបាល តុលាការ និងពន្ធនាគារ) ក្នុងការសម្របសម្រួលសកម្មភាពគម្រោងCCJAP ។ | |
| ២.១.៤ | ផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងរដ្ឋាភិបាល អំពីសកម្មភាពរបស់គម្រោង CCJAP ដែលអនុវត្តនៅក្នុងខេត្តដែលជាដៃគូ ។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| **២.២** | **ពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិ និងការអនុវត្តជាក់ស្តែងនៅក្នុងខេត្តដែលជាដៃគូ** | **គ.ជ.អ.ប** លទ្ធផលរំពឹងទុកលេខ ២<br>**LJRS 7.4.1** |
| ២.២.១ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដល់ដំណើរការផែនការវិនិយោគឃុំ និងការរៀបចំតារាងម៉ាទ្រិច សកម្មភាពអាទិភាពស្រុក សំរាប់សកម្មភាព ទ.ប.ស.ស ដោយស្រប ជាមួយនិង ក្របខណ្ឌ គ.ជ.អ.ប ។ | |
| ២.២.២ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ សំរាប់អនុវត្ត គ្រប់គ្រង និងតាមដានត្រួតពិនិត្យ សកម្មភាព ទ.ប.ស.ស អោយស្របតាមម៉ាទ្រិចសកម្មភាពអាទិភាពស្រុក ក្របខណ្ឌ គ.ជ.អ.ប និងភ្នាក់ងារអនុវត្តន៏ផ្សេងៗទៀត ។ | |
| ២.២.៣ | ប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ គ.ប្រ ដោយអនុលោមតាមអនុស្សរណៈនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារួច ដើម្បីអនុវត្តសកម្មភាព ទ.ប.ស.ស ការងារសាងសង់ និងសកម្មភាព ផ្សេងៗទៀត ដែលគាំទ្រដោយគម្រោង ។ | |
| ២.២.៤ | ផ្តល់ការគាំទ្របច្ចេកទេសនិងហិរញ្ញវត្ថុ ដល់ខេត្តដែលជាដៃគូ ដើម្បីពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតំលៃ និងរបាយការណ៏ ពីសកម្មភាពផ្នែកសន្តិសុខ និងយេនឌ័រនៅក្នុង ផែនការវិនិយោគឃុំ ដែលពាក់ព័ន្ធ ទៅនិងការងារទប់ស្កាត់បទល្មើសនិងរក្សាសុវត្ថិភាព សហគមន៏ ។ | |
| ២.២.៥ | អនុវត្តការត្រួតពិនិត្យពីហានិភ័យ ជាប្រចាំឆ្នាំ និងធ្វើសវនកម្មសកម្មភាព ដែលប្រើប្រាស់មូលនិធិបត់បែន ដោយរួមទាំងសកម្មភាពនានាដែលតម្រឹមជាមួយប្រព័ន្ធរបស់រដ្ឋាភិបាល ។ | |
| **២.៣** | **ពង្រឹងការចូលរួមនិងកិច្ចពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល នៅក្នុងខេត្តដែលជាដៃគូ** | **គ.ជ.អ.ប** លទ្ធផលរំពឹងទុកលេខ ២<br>**LJRS PA 1.4.5** |
| ២.៣.១ | សម្របសម្រួលការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល នៅក្នុងការធ្វើផែនការ រៀបចំផែនការថវិកា និងអនុវត្តន៏សកម្មភាពនៃផែនការវិនិយោគឃុំ ដែលបានអនុម័តរួច នៅក្នុងខេត្តដែល ជាដៃគូ ។ | |
| ២.៣.២ | សម្របសម្រួលកិច្ចសហការរវាងភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ជាមួយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៏ ដើម្បីរៀបចំនិងអនុវត្តសកម្មភាព ដែលឧបត្ថម្ភហិរញ្ញវត្ថុ ដោយគម្រោងCCJAP ជាពិសេសសកម្មភាពដែលគាំទ្រដល់គោលដៅអន្តរវិស័យរបស់គម្រោង ។ | |
| ២.៣.៣ | លើកកំពស់កិច្ចសហការរវាង នគរបាល តុលាការ អង្គការមិនមែនរដ្ឋាភិបាល និង ក្រសួងសុខាភិបាលដើម្បី ធ្វើការឆ្លើយតបនិងកែលំអរសេវាសំរាប់ជនរងគ្រោះដោយសារបទល្មើស ផ្លូវភេទ នៅក្នុងខេត្តដែលជាដៃគូ ។ | |
| **២.៤** | **បង្កើនការចូលរួមពីសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៏ ក្នុងការអនុវត្ត សកម្មភាពគម្រោង CCJAP នៅក្នុងខេត្តដែលជាដៃគូ** | **គ.ជ.អ.ប** លទ្ធផលរំពឹងទុកលេខ ១<br>**LJRS 1.4.5** |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| ២.៤.១ | បង្កើតបណ្តាញជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីលើកកំពស់ការអនុវត្តសកម្មភាព និង កំណត់ពីគំនិតផ្តួចផ្តើមថ្មីៗដែលចូលរួមចំណែកដល់គោលដៅរបស់គម្រោងCCJAP ។ | |
| ២.៤.២ | សហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូ ក្នុងការរៀបចំផែនការ និងអនុវត្ត គម្រោងនិងសកម្មភាពនានាដែលប្រើប្រាស់មូលនិធិបត់បែន ។ | |

## ផ្នែកទី៣ : នគរបាលជាតិកម្ពុជា

ពង្រឹងសមត្ថភាពបច្ចេកទេស ការដឹកនាំ និងយុទ្ធសាស្រ្តរបស់នគរបាលជាតិកម្ពុជា ដើម្បីកំណត់បាន និងឆ្លើយតបក្នុងលក្ខណៈ សមស្រប ចំពោះអាទិភាពរបស់សហគមន៍ ថ្នាក់ជាតិ និងក្នុងតំបន់

លទ្ធផលរំពឹងទុក

| | | |
|---|---|---|
| **៣.១** | **អនុវត្ត និងត្រួតពិនិត្យតាមដានយុទ្ធសាស្រ្តនគរបាលជាតិ និងអនុវត្តផែនការបញ្ច្រាបយេនឌ័រ** | ផែនការយុទ្ធសាស្រ្ត នគរបាលជាតិ ២០០៨-២០១៣ : ទិសដៅ ៥, ៦, ៨, ១០<br>**LJRS PA 7.5.2** |
| ៣.១.១ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអនុវត្ត និងត្រួតពិនិត្យតាមដានលើអាទិភាពសំខាន់ៗ របស់ផែនការយុទ្ធសាស្រ្តនគរបាលជាតិ ។ | |
| ៣.១.២ | គាំទ្រដល់នគរបាលជាតិ ដើម្បីអនុវត្តយុទ្ធសាស្រ្តការពារមេរោគហ៊ីវ/ជម្ងឺអេដស៍ រាប់បញ្ចូលទាំង បើកវគ្គបណ្តុះបណ្តាល ជាមួយអង្គការ HAARP ស្តីពីការកាត់បន្ថយគ្រោះថ្នាក់ ។ | |
| ៣.១.៣ | ជួយដល់ក្រុមការងារយេនឌ័រ ដើម្បីអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រ ស្របទៅតាមផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ។ | |
| ៣.១.៤ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាព និងប្រព័ន្ធត្រួតពិនិត្យវាយតម្លៃរបស់ នគរបាលជាតិនៅតាមបណ្តាខេត្តដែលជាដៃគូ លើការងារប្រមូល និងវិភាគព័ត៌មាន ទៅតាមសូចនាករ ដែលមានការឯកភាពគ្នា ដើម្បីត្រួតពិនិត្យតាមដានការអនុវត្តការងាររបស់អង្គភាព ។ | |
| **៣.២** | **បង្កើនសមត្ថភាពកោសល្យវិច្ច័យ និងប្រគល់អោយនគរបាលជាតិបន្តការគ្រប់គ្រង** | ផែនការយុទ្ធសាស្រ្ត នគរបាលជាតិ ២០០៨-២០១៣ : ទិសដៅ ៤ |
| ៣.២.១ | ផ្តល់ឧបករណ៍សម្ភារៈ និងជួយសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅតាមបណ្តា ខេត្តដែលជាដៃគូ ដើម្បីធានាការពារកន្លែងកើតហេតុ ។ | |
| ៣.២.២ | ជួយសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលជំនាញចុងក្រោយ ដល់មន្ត្រីនគរបាលបច្ចេកទេស វិទ្យាសាស្រ្តថ្នាក់ ខេត្ត ក្នុងការធ្វើកោសល្យវិច្ច័យលើវត្ថុតាង ។ | |
| ៣.២.៣ | គាំទ្រដល់ការងារអធិការកិច្ច និងការពិនិត្យឡើងវិញជាប្រចាំឆ្នាំ ដើម្បីធានាបានអំពីនិរន្តរភាព នៃជំនាញ របស់មន្ត្រី និងការគ្រប់គ្រងឧបករណ៍សម្ភារៈកោសល្យវិច្ច័យ របស់នគរបាលបច្ចេកទេសថ្នាក់ ស្រុក និងខេត្ត ។ | |
| **៣.៣** | **បង្កើនសមត្ថភាពប្រមូល និងវិភាគទិន្នន័យបទល្មើស** | ផែនការយុទ្ធសាស្រ្ត នគរបាលជាតិ |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| ៣.៣.១ | ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីអនុវត្ត ត្រួតពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធី សាកល្បង សម្រាប់ការចាប់ផ្តើមប្រើប្រាស់ទំរង់បែបបទស្រង់ទិន្នន័យបទល្មើស និងការប្រមូល វិភាគទិន្នន័យ នៅក្នុងខេត្តមួយ ឬច្រើនជាង (ដោយធានាបានថា ទិន្នន័យនោះមានបញ្ជាក់អំពី ភេទ និងអាយុ)។ | ២០០៨-២០១៣ : ទិសដៅ ៣, ៤, ៦, ៨<br>LJRS PA 7.6.1<br>LJRS PA 7.4.1<br>LJRS PA 1.7.1 |
| ៣.៣.២ | ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបន្តពង្រីកនូវការប្រើប្រាស់ទំរង់បែបបទស្រង់ទិន្នន័យ បទល្មើស ដល់គ្រប់ខេត្តទាំងអស់ដែលជាដៃគូរបស់គម្រោង ដោយមានរួមទាំងការបណ្តុះបណ្តាល និងការផ្គត់ផ្គង់ កុំព្យូទ័រ ព្រមទាំងកម្មវិធី software ដែលសមស្រប។ | |
| **៣.៤** | **គាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រទប់ស្កាត់បទល្មើស និងការងារនគរបាលសហគមន៍របស់នគរបាលជាតិកម្ពុជា និងគាំទ្រដល់ការបង្កើតគំរូការងារនគរបាលសហគមន៍** | ផែនការយុទ្ធសាស្ត្រ នគរបាលជាតិ ២០០៨-២០១៣ : ទិសដៅ ១, ៤, ១០<br>LJRS PA 7.6.2 |
| ៣.៤.១ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្កើតយុទ្ធសាស្ត្រទប់ស្កាត់បទល្មើស និងការងារ នគរបាលសហគមន៍ របស់នគរបាលជាតិកម្ពុជា។ | |
| ៣.៤.២ | ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់នគរបាលជាតិ ក្នុងការបង្កើត និងអនុវត្តន៍គំរូការងារ នគរបាលសហគមន៍មួយ សម្រាប់ប៉ុស្តិ៍នគរបាលរដ្ឋបាល តាមរយៈកម្មវិធីសាកល្បង ដកពិសោធន៍ ក្នុងខេត្ត មួយដែលជាដៃគូរបស់គម្រោង។ | |
| ៣.៤.៣ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីសាកល្បង ដើម្បី ធានាបានថា កម្មវិធីនេះទទួលបានលទ្ធផលតាមគោលបំណង។ | |
| **៣.៥** | **គាំទ្រដល់ការដាក់ឆ្លង និងការអនុវត្តន៍ច្បាប់ស្តីពីនគរបាល** | ផែនការយុទ្ធសាស្ត្រ នគរបាលជាតិ ២០០៨-២០១៣ : ទិសដៅ ១, ២, ៨, ១០<br>LJRS PA 2.1.6 |
| ៣.៥.១ | ជួយសម្របសម្រួលដល់ការដាក់ឆ្លងសេចក្តីព្រាងច្បាប់ស្តីពីនគរបាល តាមរយៈដំណាក់កាលនៃការ អនុម័តច្បាប់ ដោយរួមទាំងជំនួយផ្នែកបច្ចេកទេសក្នុងសិក្ខាសាលាផ្សព្វផ្សាយដល់ដៃគូពាក់ព័ន្ធ សំខាន់ៗ។ | |
| ៣.៥.២ | ផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការរៀបចំឧបករណ៍ផ្នែករដ្ឋបាល គោលនយោបាយ និងប្រតិបត្តិដែលចាំបាច់ ដើម្បីអនុវត្តច្បាប់នេះ តាមរយៈវិធីសាស្ត្រតាម ដំណាក់កាល។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

## ផ្នែកទី៤: ក្រសួងយុត្តិធម៌ និងតុលាការ

ពង្រឹងសមត្ថភាពក្រសួងយុត្តិធម៌ ដើម្បីជួយគាំទ្រតុលាការអោយមានប្រសិទ្ធិភាពក្នុងការផ្តល់សេវាយុត្តិធម៌អោយបានស្មើភាព និងទាន់ពេលវេលា

លទ្ធផលរំពឹងទុក

| | | |
|---|---|---|
| **៤.១** | **បង្កើនសមត្ថភាពស្ថាប័នក្រសួងយុត្តិធម៌** | LJRS PA 7.7.1<br>LJRS PA 7.5.1<br>NSDP - PFMR |
| ៤.១.១ | គាំទ្រការបង្កើតផែនការយុទ្ធសាស្ត្រក្រសួងយុត្តិធម៌។ | |
| ៤.១.២ | ផ្តល់ការគាំទ្របច្ចេកទេសចំពោះការបន្តបង្កើតផែនការសកម្មភាពក្រសួងយុត្តិធម៌។ | |
| ៤.១.៣ | ជួយក្រសួងយុត្តិធម៌ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និង អនុវត្តន៍កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។ | |
| ៤.១.៤ | ផ្តល់ការគាំទ្របច្ចេកទេស និង ហិរញ្ញវត្ថុដល់អគ្គាធិការដ្ឋានកិច្ចការតុលាការ ដើម្បីធ្វើអធិការកិច្ចរដ្ឋបាល តុលាការ (តុលាការគំរូ និង តុលាការនៅក្នុងខេត្តដែលជាដៃគូ)។ | |
| ៤.១.៥ | ផ្តល់ការគាំទ្របច្ចេកទេស និង ហិរញ្ញវត្ថុដល់នាយកដ្ឋានអយ្យការនៃក្រសួងយុត្តិធម៌ ដើម្បីត្រួតពិនិត្យការងារ អប់រំកែប្រែ។ | |
| ៤.១.៦ | គាំទ្រក្រុមការងារសកម្មភាពបញ្ច្រាបយេនឌ័រ ដើម្បីអនុវត្តផែនការសកម្មភាពបញ្ច្រាបយេនឌ័រ។ | |
| ៤.១.៧ | គាំទ្រការលើកកំពស់ការយល់ដឹង និង អប់រំ ដល់បុគ្គលិកបំរើការងារនៅក្នុងក្រសួងយុត្តិធម៌ និង តុលាការ ពីមេរោគហ៊ីវ/ជំងឺអេដស៍ និងផលប៉ះពាល់នានា។ | |
| **៤.២** | **បង្កើត និង អនុវត្តនីតិវិធីនានានៃប្រព័ន្ធតុលាការកម្ពុជា** | LJRS PA 5.3.2<br>LJRS PA 5.3.3 |
| ៤.២.១ | គាំទ្រការធ្វើឱ្យប្រសើឡើងនូវការគ្រប់គ្រងទិន្នន័យ និង វិធីសាស្ត្រនានាសំរាប់រឿងក្តីព្រហ្មទណ្ឌ (រួមទាំង រឿងក្តីអនីតិជន) នៅក្នុងតុលាការ។ | |
| ៤.២.២ | ជួយក្រសួងយុត្តិធម៌ ដើម្បីបង្កើតគោលការណ៍ និង ច្បាប់ ដើម្បីគ្រប់គ្រងរដ្ឋបាលតុលាការ។ | |
| ៤.២.៣ | គាំទ្រការបង្កើតប្រព័ន្ធសំរាប់ការផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវសាលក្រមរបស់សាលាឧទ្ធរណ៍ និងតុលាការកំពូល។ | |
| ៤.២.៤ | ជួយក្រសួងយុត្តិធម៌ ដើម្បីបង្កើតវិធានការនានា ដើម្បីធានាថាការឃុំខ្លួនគឺស្ថិតនៅក្រោមអំណាចតុលាការ និង ត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាពដោយអគ្គាធិការដ្ឋានកិច្ចការតុលាការ និង នាយកដ្ឋានអយ្យការ រួមទាំង ធានាចំពោះការចេញសាលក្រមស្ថាពរ និងការត្រួតពិនិត្យការឃុំខ្លួនបណ្តោះអាសន្ន និងក្រោយការកាត់ក្តី។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| ៤.២.៥ | ធ្វើការរួមគ្នាជាមួយផ្នែកផ្សេងៗទៀត ក្នុងការគាំទ្រការបង្កើតពិធីសារ និងយន្តការនានាសំរាប់កិច្ចសហ ប្រតិបត្តិការរវាង តុលាការ នគរបាល និង ពន្ធនាគារ ទៅលើបញ្ហានានាដូចជា កោសល្យវិច្ឆ័យវេជ្ជសាស្ត្រ ការរក្សាវត្ថុតាង ការគាំទ្រជនរងគ្រោះ និងការគ្រប់គ្រងជនសង្ស័យ ។ | |
| **៤.៣** | **ពិនិត្យកែសម្រួលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរឿងក្តីសាលាឧទ្ធរណ៍ និង ដាក់ឱ្យអនុវត្តនូវប្រព័ន្ធថ្មី** | **LJRS PA 5.3.3** |
| ៤.៣.១ | ជួយបុគ្គលិកសាលាឧទ្ធរណ៍ បង្កើតប្រព័ន្ធទិន្នន័យ និង យន្តការរាយការណ៍សមស្រប ។ | |
| ៤.៣.២ | គាំទ្រការអនុវត្តជាក់ស្តែង និង ការអនុវត្តនីតិវិធី ដើម្បីគ្រប់គ្រងរឿងក្តី នៅក្នុងសាលាឧទ្ធរណ៍ ។ | |
| ៤.៣.៣ | ជួយសាលាឧទ្ធរណ៍បង្កើតលេខាធិការដ្ឋានតុលាការ ។ | |
| ៤.៣.៤ | ជួយសាលាឧទ្ធរណ៍បង្កើតយុទ្ធសាស្ត្រហេដ្ឋារចនាសម្ព័ន្ធ ។ | |
| **៤.៤** | **សហការជាមួយខេត្តដែលជាដៃគូ ក្នុងការគាំទ្រ កិច្ចប្រជុំរវាង នគរបាល តុលាការ និង ពន្ធនាគារ** | **LJRS PA 7.6.2** |
| ៤.៤.១ | គាំទ្រការអនុវត្តកិច្ចប្រជុំរវាង នគរបាល អយ្យការ តុលាការ និងពន្ធនាគារ សំរាប់តុលាការនានា នៅតាម ខេត្តដែលជាដៃគូ និងនៅរាជធានីភ្នំពេញ ។ | |
| ៤.៤.២ | សំរបសំរួលប្រព័ន្ធពតិមាន ដែលអាចចែករំលែកបទពិសោធន៍ នៃកិច្ចប្រជុំរវាង នគរបាល អយ្យការ តុលាការ និង ពន្ធនាគារ ដើម្បីគាំទ្របន្តទៅលើការបង្កើតទស្សនៈទានតុលាការគំរូ ។ | |
| **៤.៥** | **គាំទ្រការអនុវត្តរបស់តុលាការគំរូ** | **LJRS PA 5.3.2** |
| ៤.៥.១ | គាំទ្រក្រសួងយុត្តិធម៌ក្នុងក្រុមការងារតុលាការគំរូ រួមទាំងការពិនិត្យមើលការរៀបចំស្នើសុំថវិកាជាតិសំរាប់ អនុវត្តការងារ ។ | |
| ៤.៥.២ | គាំទ្រការបង្កើតយុទ្ធសាស្ត្រហេដ្ឋារចនាសម្ព័ន្ធ សំរាប់សាលាដំបូង ។ | |
| **៤.៦** | **គាំទ្រក្រុមការងារយុត្តិធម៌អនីតិជន** | **LJRS PA 2.2.3** |
| ៤.៦.១ | ផ្តល់ការគាំទ្របច្ចេកទេស ដើម្បីបញ្ចប់ពង្រាងច្បាប់យុត្តិធម៌អនីតិជន ។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| **ផ្នែកទី៥: សេវាអប់រំកែប្រែអ្នកទោស**<br>ពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីកំណត់ និងឆ្លើយតបទៅនឹង អាទិភាពនានាក្នុងការគ្រប់គ្រងពន្ធនាគារ តំរូវការសំរាប់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកទោស ព្រមទាំងកំណត់ពីជម្រើសផ្សេងៗសំរាប់កំណែទម្រង់ពន្ធនាគារ | | |
| លទ្ធផលរំពឹងទុក | | |
| **៥.១** | **សមត្ថភាពរចនាសម្ព័ន្ធចាត់តាំងក្នុងអគ្គនាយកដ្ឋានពន្ធនាគារត្រូវបានអភិវឌ្ឍន៏** | **អគ្គនាយកដ្ឋានពន្ធនាគារ**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១៣: គោលបំណងទី១ ទី២ និងទី៤<br>LJRS PA 2.1.8<br>LJRS PA 7.7.1 |
| ៥.១.១ | ជួយគាំទ្រដល់អគ្គនាយកដ្ឋានពន្ធនាគារបន្តអភិវឌ្ឍន៏សេចក្ដីព្រាងច្បាប់ពន្ធនាគារ និងបទដ្ឋានច្បាប់នានា ស្របតាមបទដ្ឋានច្បាប់របស់កម្ពុជា។ | |
| ៥.១.២ | ជួយគាំទ្រដល់ការអនុវត្តច្បាប់ពន្ធនាគារថ្មី រួមទាំងការពិនិត្យកែសម្រួលនីតិវិធីគ្រប់គ្រងពន្ធនាគារ និងបទដ្ឋានច្បាប់នានា។ | |
| ៥.១.៣ | ជួយគាំទ្រដល់ក្រុមការងារយេនឌ័រ ដើម្បីអនុវត្តផែនការសកម្មភាពយេនឌ័រ។ | |
| ៥.១.៤ | សម្របសម្រួលក្នុងការអភិវឌ្ឍន៏ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង និងថ្នាក់ប្រតិបត្តិការ បច្ចេកទេស។ | |
| ៥.១.៥ | គាំទ្រការអនុវត្តនីតិវិធីតាមដានមូលដ្ឋាន និងគោលការណ៏ណែនាំនានា ដើម្បីអភិវឌ្ឍន៏ការិយាល័យតាមដាន មូលដ្ឋាន ដោយផ្តោតលើសិទ្ធិសុខពន្ធនាគារ និងកម្មវិធីស្តារនីតិសម្បទាអ្នកទោសនៅតាមពន្ធនាគារដែលជាដៃគូ។ | |
| ៥.១.៦ | ផ្តល់ការគាំទ្រដល់ការិយាល័យស្ថាបនា ដើម្បីធ្វើអោយការអនុវត្តនីតិវិធី និងគោលការណ៏ណែនាំនានារបស់ ការិយាល័យនេះ មានភាពល្អប្រសើរ និងធានាឱ្យកម្មវិធីសាងសង់មាននិរន្តភាព។ | |
| ៥.១.៧ | ធ្វើការវិភាគអំពីផលប៉ះពាល់ដែលបណ្តាលមកពីភាពចង្អៀតណែន ដោយសហការជាមួយអង្គការកក្កបាទក្រហមអន្តរជាតិ និងអគ្គនាយកដ្ឋានពន្ធនាគារ។ | |
| **៥.២** | **ធ្វើអោយសេវាសុខភាពក្នុងពន្ធនាគារមានភាពល្អប្រសើរ** | **អគ្គនាយកដ្ឋានពន្ធនាគារ**<br>ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១៣: គោលបំណងទី១ គោលដៅ ១.២<br>NSDP – HIV/AIDS<br>LJRS PA 1.2.1 |
| ៥.២.១ | សហការជាមួយក្រសួងសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តសេវាសុខភាពសម្រាប់ អ្នកទោស ដើម្បីឆ្លើយតបបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ និងរបេង ក្នុងពន្ធនាគារដែលជាដៃគូ។ | |
| ៥.២.២ | សហការជាមួយក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ សើស្បែក និងកាមរោគ និងមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងអប់រំពីបញ្ហាសុខភាពដល់មន្ត្រីពន្ធនាគារ និងអ្នកទោសអំពីការបង្ការជាសកល និងការកាត់បន្ថយគ្រោះថ្នាក់។ | |
| ៥.២.៣ | ផ្តល់ការបណ្តុះបណ្តាល និងបំពាក់សម្ភារៈបច្ចេកទេសសំរាប់បង្កើតទិន្នន័យសុខភាព និងពតិមានស្ថិតិនៅតាម ពន្ធនាគារដែលជាដៃគូ។។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| ៥.២.៤ | ជួយគាំទ្រដល់ការកែលំអប៉ុស្តិ៍សុខភាព រួមទាំងការសាងសង់ថ្មី ជួសជុល និងបំពាក់សម្ភារៈបរិក្ខាពេទ្យនៅតាមពន្ធនាគារដែលជាដៃគូ។ | |
| **៥.៣** | **កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មអ្នកទោសត្រូវបានអនុវត្ត** | **អគ្គនាយកដ្ឋានពន្ធនាគារ** |
| ៥.៣.១ | រៀបចំអនុវត្តវេទិកាអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ពន្ធនាគារខេត្ត (ខេត្តដែលជាដៃគូ) និងមណ្ឌលអប់រំកែប្រែ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនូវរាល់សកម្មភាពស្តារនីតិសម្បទា។ | ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១៣: គោលបំណងទី៣ គោលដៅ ៣.១ , ៣.២ , ៣.៣ , ៣.៤<br>LJRS PA 1.4.5 |
| ៥.៣.២ | កែលម្អកម្មវិធីឧស្សាហកម្ម និងកសិកម្មពន្ធនាគារមានភាពល្អប្រសើរ តាមរយៈការជួយសាងសង់ និងជួសជុលទីកន្លែង និងបំពាក់សម្ភារៈសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារផលិតកម្មសម្រាប់ពន្ធនាគារដែលជាដៃគូ។ | |
| ៥.៣.៣ | សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីធ្វើអោយអ្នកទោសជាអនីតិជនទទួលបាននូវកម្មវិធីនានាក្នុងពន្ធនាគារដែលជាដៃគូ។ | |
| ៥.៣.៤ | សហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីធ្វើអោយអ្នកទោសជាស្ត្រីទទួលបានកម្មវិធីនានាក្នុងពន្ធនាគារដែលជាដៃគូ។ | |
| ៥.៣.៥ | ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍ និងអនុវត្តនូវគំនិតផ្តួចផ្តើមការស្តារនីតិសម្បទាថ្មីៗ ដែលបានកំណត់នៅក្នុងក្របខណ្ឌគោលនយោបាយកំណែទម្រង់នៅតាមពន្ធនាគារជាដៃគូ។ | |
| **៥.៤** | **ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារត្រូវបានកែលម្អ ដើម្បីដោះស្រាយភាពចង្អៀតណែន និងជួយគាំទ្រ ដល់កំណែទម្រង់ពន្ធនាគារ** | **អគ្គនាយកដ្ឋានពន្ធនាគារ** |
| ៥.៤.១ | អនុវត្តការជួសជុល និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាឱ្យស្របតាមបទដ្ឋានថ្មីរបស់អគ្គនាយកដ្ឋាន ពន្ធនាគារ នៅតាមបណ្តាពន្ធនាគារជាដៃគូ ដើម្បីដោះស្រាយភាពចង្អៀតណែន។ | ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១៣: គោលបំណងទី៤ គោលដៅ ៤.១ , ៤.២ |
| ៥.៤.២ | ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍ និងអនុវត្តនូវគំនិតផ្តួចផ្តើមថ្មីៗ ដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារដើម្បីជួយគាំទ្រដល់ការដាក់បំបែកអ្នកទោសដោយឡែកពីគ្នា នៅតាមបណ្តាពន្ធនាគារជាដៃគូ។ | |
| ៥.៤.៣ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ អគ្គនាយកដ្ឋានពន្ធនាគារក្នុងការអភិវឌ្ឍន៍ និងអនុវត្តពន្ធនាគារកសិកម្មថ្មី (មណ្ឌលអប់រំកែប្រែទី៤) | |
| **៥.៥** | **ភាពជាដៃគូជាមួយអគ្គនាយកដ្ឋានពន្ធនាគារត្រូវបានពង្រឹង** | **អគ្គនាយកដ្ឋានពន្ធនាគារ** |
| ៥.៥.១ | ផ្តល់ការគាំទ្រតាមរយៈការលើកស្ទួយឱ្យអង្គការសង្គមស៊ីវិលមានកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានពន្ធនាគារបានកាន់តែច្រើន។ | ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១៣: គោលបំណងទី៣ គោលដៅ |
| ៥.៥.២ | ផ្តល់ការគាំទ្រធ្វើអោយមានកិច្ចសហប្រតិបត្តិការអន្តរក្រសួងជាមួយអគ្គនាយកដ្ឋានពន្ធនាគារបានកាន់តែច្រើន។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| | | ៣.១ , ៣.២ , ៣.៣<br>LJRS PA 1.4.5 |
| **ផ្នែកទី៦ ៖ ក្រុមគាំទ្រការងារគ្រប់គ្រងគម្រោង និងមូលនិធិបត់បែន** | | |
| ជួយគាំទ្រការអនុវត្តគម្រោងអោយមានប្រសិទ្ធភាព សំរេចបានលទ្ធផល មានគណនេយ្យភាពក្នុងការប្រើប្រាស់ធនធាន និងធ្វើអោយផលប្រយោជន៍ របស់គម្រោងមាននិរន្តរភាព | | |
| លទ្ធផលរំពឹងទុក | | |
| **៦.១** | **អនុវត្តផែនការដែលពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រងហានិភ័យដើម្បីធានាបានថា ឧបស័គ្គដែល រារាំងដល់ភាពជោគជ័យ របស់គម្រោងត្រូវបានកាត់បន្ថយ** | |
| ៦.១.១ | រៀបចំប្រជុំពិគ្រោះយោបល់និងសិក្ខាសាលាដើម្បីពិនិត្យឡើងវិញនូវប្រសិទ្ធិភាពនៃផែនការការងារ ប្រចាំឆ្នាំ២០១០ (០១ មករា ២០១០ ដល់ ៣១ ធ្នូ ២០១០) ។ | |
| ៦.១.២ | ធ្វើការវាយតំលៃជាបន្តបន្ទាប់លើហានិភ័យ ដោយរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ អោយមាន ប្រសិទ្ធិភាព ហើយធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យតាមតម្រូវការ ។ | |
| ៦.១.៣ | អនុវត្តជាបន្តបន្ទាប់នូវការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រទំនាក់ទំនង និងគេហទំព័រ ដើម្បីធានាបាន ការប្រាស្រ័យទាក់ទងគ្នា នូវព័ត៌មានសំខាន់ៗ ទាន់ពេលវេលា ។ | |
| ៦.១.៤ | សហការជាមួយដៃគូពាក់ព័ន្ធ និងបុគ្គលិកគម្រោង រៀបចំផែនការប្រចាំឆ្នាំ ២០១១ ។ | |
| ៦.១.៥ | រៀបចំបង្កើតយុទ្ធសាស្ត្រនិរន្តរភាពរបស់គម្រោង និងទទួលបានការឯកភាពពី AusAID និង ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ។ | |
| **៦.២** | **គ្រប់គ្រងបុគ្គលិក និងធនធានគម្រោង ប្រកបដោយប្រសិទ្ធិភាព ។** | |
| ៦.២.១ | គ្រប់គ្រងនិងអភិវឌ្ឍការងាររបស់បុគ្គលិកគម្រោង ដោយយោងទៅតាមក្បួននីតិវិធីរបស់គម្រោង ។ | |
| ៦.២.២ | រៀបចំការងារអោយទីប្រឹក្សារយៈពេលខ្លី អោយបានទាន់ពេលវេលា និងណែនាំអំពីទិសដៅ និង កិច្ចការរបស់គម្រោង អោយពេញលេញតាមតម្រូវការ ។ | |
| ៦.២.៣ | ជ្រើសរើសបុគ្គលិកគម្រោងដោយយោងទៅតាមក្បួននីតិវិធី ។ | |
| ៦.២.៤ | ធ្វើការប្រជុំ ជាមួយទីប្រឹក្សា មន្ត្រីគម្រោង និងក្រុមបុគ្គលិកគម្រោងអោយបានទៀងទាត់ ។ | |
| **៦.៣** | **ប្រព័ន្ធរដ្ឋបាលនិងហិរញ្ញវត្ថុប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព ដើម្បីគាំទ្រដល់ដំណើរការ និង ការគ្រប់គ្រងគម្រោង** | |
| ៦.៣.១ | ពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពអោយបានទៀងទាត់លើក្បួននីតិវិធីប្រព័ន្ធរដ្ឋបាលនិងហិរញ្ញវត្ថុរបស់គម្រោង ។ | |
| ៦.៣.២ | បន្តការងារគ្រប់គ្រងចាត់ចែង នូវតម្រូវការផ្នែកភស្តុភារនិងរដ្ឋបាលរបស់គម្រោង រួមមានការធ្វើ លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ និងការទូទាត់ចំណាយផ្សេងៗ ។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | |
|---|---|
| ៦.៣.៣ | ធ្វើសវនកម្មប្រព័ន្ធហិរញ្ញវត្ថុរបស់គម្រោង ទៅតាមការកំណត់ច្បាស់លាស់និងករណីពិសេស (រួមមានមូលនិធិបត់បែន) |
| **៦.៤** | **ប្រតិបត្តិយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាព ដែលមានរាប់បញ្ចូលទាំងក្រុមប្រឹក្សា ភិបាលជាតិ គ្រប់គ្រងគម្រោង** |
| ៦.៤.១ | ផ្តល់ការគាំទ្រនិងធ្វើទំនាក់ទំនងជាបន្តបន្ទាប់ជាមួយក្រុមការងាររបស់ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍនានា អង្គការមិនមែនភិបាល និងបេសកកម្មនានា ដែលពាក់ព័ន្ធ។ |
| ៦.៤.២ | ជួយគាំទ្រដល់លេខាធិការដ្ឋាន ក្នុងការងារប្រតិបត្តិការរបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង។ |
| ៦.៤.៣ | ជួយគាំទ្រដល់ការរៀបចំធ្វើរបាយការណ៍ប្រចាំឆមាសសំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ពិនិត្យ។ |
| **៦.៥** | **មូលនិធិបត់បែន ប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព** |
| ៦.៥.១ | ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំមូលនិធិបត់បែនដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងអនុម័តតាម តម្រូវការ។ |
| ៦.៥.២ | គ្រប់គ្រងប្រតិបត្តិការមូលនិធិបត់បែនអោយមានតម្លាភាពនិងប្រសិទ្ធិភាព ដើម្បីងាយស្រួលដល់ការធ្វើ សវនកម្មប្រចាំឆ្នាំ។ |
| ៦.៥.៣ | ផ្តល់ការបណ្តុះបណ្តាលនិងការស្វែងយល់ជាបន្តបន្ទាប់ទៅអោយសមភាគីនិងអង្គការក្រៅរដ្ឋាភិបាលដែល ពាក់ព័ន្ធស្តីពីគោលការណ៍ណែនាំមូលនិធិបត់បែន។ |
| **៦.៦** | **អនុវត្តប្រកបដោយប្រសិទ្ធិភាពនូវក្របខណ្ឌត្រួតពិនិត្យតាមដានរបស់គម្រោង** |
| ៦.៦.១ | ពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពផែនការត្រួតពិនិត្យនិងវាយតំលៃ និងចងក្រងមូលដ្ឋានទិន្នន័យតាមតម្រូវការ។ |
| ៦.៦.២ | ក្រុមគម្រោងសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ពិនិត្យឡើងវិញនូវវិធីសាស្រ្តនានា ការទទួលខុសត្រូវ និង ឧបករណ៍ត្រួតពិនិត្យតាមដាន។ |
| ៦.៦.៣ | រៀបចំនិងដាក់អោយអនុវត្តការស្ទង់មតិបែបគុណភាព ប្រចាំឆ្នាំ។ |
| ៦.៦.៤ | រៀបចំរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ។ |
| **៦.៧** | **អនុវត្តយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រ** |
| ៦.៧.១ | អនុវត្ត ពិនិត្យតាមដាននិងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពបញ្ជ្រាបយេនឌ័ររបស់គម្រោង និង សកម្មភាព អន្តរវិស័យ |
| **៦.៨** | **អនុវត្តយុទ្ធសាស្រ្តយុត្តិធម៌អនីតិជន** |
| ៦.៨.១ | អនុវត្ត ពិនិត្យតាមដាននិងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពយុទ្ធសាស្រ្តយុត្តិធម៌អនីតិជនររបស់គម្រោង និង សកម្មភាពអន្តរវិស័យ |
| **៦.៩** | **អនុវត្តយុទ្ធសាស្រ្តមេរោគហ៊ីវ/ជម្ងឺអេដស៍** |
| ៦.៩.១ | អនុវត្ត ពិនិត្យតាមដាននិងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពយុទ្ធសាស្រ្តមេរោគហ៊ីវ/ ជំងឺអេដស៍ របស់គម្រោង និង សកម្មភាពអន្តរវិស័យ។ |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| | | |
|---|---|---|
| **៦.១០** | **កម្មវិធីសំណង់-សិក្សាគម្រោង និងការអនុវត្ត** | |
| ៦.១០.១ | តាមដានត្រួតពិនិត្យគម្រោងសាងសង់ និង សវនកម្ម ជាមួយមូលនិធិបត់បែន ។ | |
| ៦.១០.២ | អនុវត្តការងារសាងសង់ ជាមួយផ្នែកនគរបាលជាតិ ផ្នែកតុលាការ នៅថ្នាក់ជាតិ និង ពន្ធនាគារថ្នាក់ខេត្ត ដែលតម្រឹមជាមួយការពង្រឹងនីតិវិធីលទ្ធកម្មនិងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ | |
| ៦.១០.៣ | អនុវត្តន៏គម្រោងសាងសង់ខ្នាតតូចដែលគាំទ្រដល់ក្រុមជនដែលងាយរងគ្រោះជនរងគ្រោះដោយបទល្មើស និងយុត្តិធម៌អនីតិជន។ | |

*LJRS PA: សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌*

*NSDP: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ*

*PFMR: : កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*